ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី៤ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧

រៀបចំដោយ៖ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយ៖ ថវិកាជាតិ

## ១. សេចក្តីផ្តើម៖

នៅព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៤ សម្រាប់ឆ្នាំ២០១៧ ក្រោមការដឹកនាំរបស់ **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើការងារមេរោគអេដស៍ និងជំងឺអេដស៍។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## ២. គោលបំណងនៃកិច្ចប្រជុំ៖

ដើម្បីបង្ហាញពីរបាយការណ៍វឌ្ឍនភាព សមិទ្ធផល និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈ ដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំ

-របាយការណ៍ប្រចាំខែ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បទបង្ហាញពីការអង្កេត ជីវសាស្ត្រ រកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ និងការប្រព្រឹត្តផ្លូវភេទក្នុងចំណោមស្ត្រីបំរើសេវាកម្សាន្តឆ្នាំ២០១៦ នៅកម្ពុជា។

-និងបញ្ហាផ្សេងៗ។

## ៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមវេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក-សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។

**<u>ប្រធានបទទី១៖</u> ឯកឧត្តមវេជ្ជបណ្ឌិត ជា ប៉ោ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីរបាយការណ៍សង្ខេបរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានអនុវត្តនៅក្នុងខែឧសភា ឆ្នាំ២០១៧ ដូចខាងក្រោម៖

- ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានអញ្ជើញជាអធិបតីភាពក្នុងពិធីប្រកាសកិច្ចសហប្រតិបត្តិការលើគម្រោងបង្ការការចម្លងមេរោគអេដស៍ រវាងនាយកដ្ឋានសុខាភិបាល នៃអគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ ក្រសួងការពារជាតិ និងអង្គការមូលនិធិថែទាំសុខភាពអ្នកជំងឺអេដស៍(AHF) និងប្រកាសឯកអគ្គរដ្ឋទូតសុច្ឆន្ទៈសម្រាប់ការងារផ្សព្វផ្សាយអប់រំស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** បានថ្លែងការកោតសរសើរដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃក្រសួងការពារជាតិ ដែលបានផ្តួចផ្តើមគម្រោងផ្សព្វផ្សាយអប់រំ អំពីសុវត្ថិភាព និងការបង្ការការឆ្លង

មេរោគអេដស៍ ក្នុងចំណោមកងយោធពលខេមរភូមិន្ទ និងក្រុមគ្រួសាររបស់កងទ័ព ជាមួយអង្គការមូលនិធិថែទាំសុខភាពអ្នកជំងឺអេដស៍។ ជាមួយគ្នានោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានថ្លែងកោតសរសើរ និងអបអរសាទរចំពោះក្មួយៗជាសិល្បៈករ សិល្បៈការនី ដែលបានស្ម័គ្រចិត្ត លះបង់ពេលវេលា ទាំងកំលាំងកាយចិត្ត ចូលរួមចំណែកក្នុងការងារផ្សព្វផ្សាយអប់រំ ចែកចាយព័ត៌មានដែលត្រឹមត្រូវ ដើម្បីបង្ការ និងទប់ស្កាត់ការចម្លងមេរោគអេដស៍ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ក្នុងចំណោមកងយោធពលខេមរភូមិន្ទ ក៏ដូចជាក្នុងចំណោមប្រជាពលរដ្ឋទូទៅ ហើយដែលត្រូវបានតែងតាំងជាឯកអគ្គរដ្ឋទូតសុច្ឆន្ទៈ សម្រាប់កិច្ចការមនុស្សធម៌ដ៏មានតម្លៃនាពេលនេះ និងបានជូនពរឱ្យគម្រោងផ្សព្វផ្សាយអប់រំបង្ការការចម្លងមេរោគអេដស៍ បានទទួលជោគជ័យតាមផែនការ។

- ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានគណៈកម្មាធិការសម្របសម្រួលគម្រោងមូលនិធិសកលកម្ពុជា(CCC) បានអញ្ជើញជាអធិបតី បិទកិច្ចប្រជុំពិគ្រោះយោបល់នៃតំណាងសហគមន៍ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល លើគម្រោងកម្មវិធីស្នើសុំជំនួយពីមូលនិធិសកល ដើម្បីបន្តប្រយុទ្ធនឹងជំងឺអេដស៍ សម្រាប់ឆ្នាំ២០១៨-២០២០។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានមានប្រសាសន៍ថានឹងជួយជ្រោមជ្រែង សម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ម្ចាស់ជំនួយជាបន្តទៀត ដើម្បីឱ្យកង្វល់ កង្វះថវិកា និងខ្លឹមសារនៃកិច្ចប្រជុំនាពេលនេះ ត្រូវបានពិចារណា និងដាក់បញ្ចូលជាបទអន្តរាគមន៍សំខាន់ ជាអាទិភាពក្នុងគម្រោងកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍។
- ថ្ងៃទី០២-០៥ ខែឧសភា ឆ្នាំ២០១៧ អគ្គលេខាធិការដ្ឋានបានចុះអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ស្តីពីការបង្កបរិយាកាសអំណោយផល និងការអនុវត្តន៍កម្មវិធីដៃគូសហគមន៍ សម្រាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់នៅខេត្តកំពង់ចាម ដោយបានជួបពិភាក្សាការងារជាមួយលោកប្រធានលេខាធិការដ្ឋាន និងប្រធានការិយាល័យប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត អង្គការក្រៅរដ្ឋាភិបាល និងមន្ទីរមួយចំនួន ដូចជាមន្ទីរកិច្ចការនារី មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរផែនការ។ នៅក្នុងជំនួបនីមួយៗបានបង្ហាញពីសកម្មភាពការងារដែលទាក់ទងនឹងបញ្ហាមេរោគអេដស៍ និងគ្រឿងញៀន កុមារកំព្រា ការធ្វើចំណាកស្រុក ក្រុមប្រឈមមុខខ្ពស់ ការផ្តល់អត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងឃុំនីមួយៗ និងកិច្ចសហការរវាងក្រុមការងារបច្ចេកទេសរបស់មន្ទីរសុខាភិបាល ជាមួយអន្តរមន្ទីរ អាជ្ញាធរមូលដ្ឋាន និងអង្គការនៅតាមសហគមន៍ ក្នុងការអនុវត្តន៍បទអន្តរាគមន៍បង្ការលើក្រុមប្រឈមមុខខ្ពស់ ក្នុងខេត្ត។
- ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ ឯកឧត្តមអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមកិច្ចប្រជុំសម្របសម្រួលរវាងម្ចាស់ និងតំណាងគ្រឹះស្ថានសេវាកម្សាន្តសប្បាយ ជាមួយបុគ្គលិកអប់រំពីការបង្ការ និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយមានការចូលរួមផងដែរពីលោកអភិបាលរងខណ្ឌជ្រោយចង្វា អាជ្ញាធរឃុំ-សង្កាត់ សមត្ថកិច្ចមូលដ្ឋាន លោកនាយកអង្គការខាណា និងលោកស្រីតំណាងមន្ទីរសុខាភិបាលរាជធានីភ្នំពេញ។ ក្រោយពីការពិភាក្សា យើងបានដោះស្រាយនូវចំណុចជាឧបសគ្គមួយចំនួន និងសន្យាបន្តចូលរួមអនុវត្តបន្ថែមទៀត ។

- ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧ ឯកឧត្តមអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានធ្វើការផ្សព្វផ្សាយពីបច្ចុប្បន្នភាពនៃការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ជូនដល់និស្សិតនាយទាហានសកម្មដែលជាអ្នកបន្តវេន ដែលបានរៀបចំឡើងដោយនាយកដ្ឋានសុខាភិបាល ក្រសួងការពារជាតិ។ ឯកឧត្តម បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះឯកឧត្តមនាយករងសាលានាយទាហានសកម្ម និងថ្នាក់ដឹកនាំទាំងអស់ ដែលបានផ្តល់នូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ។
- ថ្ងៃទី២២-២៣ ខែឧសភា ឆ្នាំ២០១៧ នាខេត្តព្រះសីហនុ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមជាគ្រូឧទ្ទេសនាម ក្នុងអង្គសិក្ខាសាលាស្តីពីការបញ្ជ្រាបកម្មវិធីឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមអ្នកសារព័ត៌មាន វិទ្យុ ទូរទស្សន៍ និងវិស័យឯកជន។
- ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលស្តីពីការអង្កេត ស្រាវជ្រាវចំណេះដឹងអំពីជំងឺអេដស៍ ការប្រព្រឹត្តផ្លូវភេទ និងរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមនារីបម្រើតាមសេវាកម្សាន្តសប្បាយនៅក្នុងប្រទេសកម្ពុជា នៅសណ្ឋាគារភ្នំពេញ។
- ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ អគ្គលេខាធិការដ្ឋានបានចូលរួមការពិភាក្សា ក្នុងការតស៊ូមតិស្វែងរកការគាំទ្រពីរាជរដ្ឋាភិបាលរបស់ក្រុមអ្នកស្រលាញ់ភេទដូចគ្នា ដែលមានការអញ្ជើញចូលរួមពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តំណាងក្រសួងយុត្តិធម៌ គណៈកម្មាធិការសិទ្ធមនុស្សកម្ពុជា លោកជំទាវតំណាងក្រសួងកិច្ចការនារី និងតំណាងអង្គការសហប្រជាជាតិ ( UNAIDS & UN WOMEN ) នៅកម្ពុជា ។

**<u>ផែនការសកម្មភាព និងទិសដៅបន្ត៖</u>**

- បន្តរៀបចំឯកសារ និងទំនាក់ទំនងជាមួយបណ្តាខេត្តមួយចំនួន សម្រាប់ការចុះអភិបាលកិច្ច នៅថ្នាក់ក្រោមជាតិ និងសិក្ខាសាលាស្តីពីការបង្កបរិយាកាសអំណោយផល និងការអនុវត្តន៍កម្មវិធីដៃគូសហគមន៍សម្រាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់ ។
- បន្តតាមដាន និងពិនិត្យរាល់ការអនុវត្តន៍ការងារឆ្លើយតបទៅនឹងការកាត់បន្ថយការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ របស់រាជធានី-ខេត្ត និងស្ថាប័នពាក់ព័ន្ធ។
- បន្តចូលរួមរៀបចំកិច្ចប្រជុំលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ និងរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រចាំខែ។
- បន្តតាមដានលិខិតជូនដំណឹងទៅគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី-ខេត្ត ទាក់ទងនឹងការប្រជុំតាមបណ្តារាជធានី-ខេត្ត និងការប្រមូលចងក្រងទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រសម្រាប់ឆ្នាំ២០១៧។
- បន្តរៀបចំការងារទាក់ទងនឹងកិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ២០១៧ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៧។

➢ បន្តការងារទាក់ទងជាមួយក្រសួងព័ត៌មានស្តីពីសំណើជួយផ្សព្វផ្សាយសារអប់រំស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈការរត់អក្សរនៅលើកញ្ចក់ទូរទស្សន៍នានា ជាពិសេសទូរទស្សន៍ជាតិកម្ពុជា នៅក្នុងឱកាសព្រឹត្តិការណ៍សំខាន់ៗ បុណ្យជាតិនានា និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ។

ក្រោយពីបង្ហាញចប់ **ឯកឧត្តមប្រធានអង្គប្រជុំ** បានស្នើឱ្យបន្ថែមនូវសកម្មភាពដែលសមាជិកក្រុមការងារបានធ្វើកន្លងមក សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**តំណាងក្រសួងបរិស្ថាន** ៖ បានសហការជាមួយសម្ព័ន្ធយុវជនកម្ពុជាតាមរយៈការបោះតង់ នៅកោះរុង ខេត្តព្រះសីហនុ ដោយបានបញ្ជ្រាបពីបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ ជាពិសេសការបង្ការការចម្លងមេរោគអេដស៍ដល់ក្រុមយុវជន។

**តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម** ៖

- ✓ បានចុះសួរសុខទុក្ខមន្ត្រីរាជការដែលមានផ្ទុកមេរោគអេដស៍ចំនួន៣ខេត្ត គឺខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តពោធិ៍សាត់។
- ✓ បានចុះផ្សព្វផ្សាយពីបញ្ហាមេរោគអេដស៍ និងជំងឺអេដស៍ ដល់មន្ត្រីរាជការ ឧស្សាហករ សិប្បករ ពាណិជ្ជករ សេវាករបានចំនួន៤ខេត្ត គឺខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់។
- ✓ បានចុះបិទសារប្រយុទ្ធនឹងជំងឺអេដស៍ នៅតាមមូលដ្ឋានផលិតកម្មមួយចំនួនក្នុងខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់។

**តំណាងក្រសួងការពារជាតិ** ៖បានចុះទៅធ្វើតេស្តឈាមរកមេរោគអេដស៍ ជាមួយអង្គការ AHF ក្នុងចំណោមកងយោធពលខេមរភូមិន្ទ ចំនួនប្រហែល១០០០នាក់ ក្នុងនោះតេស្តវិជ្ជមានចំនួន១០នាក់។

**ប្រធានបទទី២**៖ បទបង្ហាញពីការអង្កេត ជីវសាស្ត្រ រកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ និងការប្រព្រឹត្តផ្លូវភេទក្នុងចំណោមស្ត្រីបំរើសេវាកម្សាន្តឆ្នាំ២០១៦ នៅកម្ពុជា ដោយ**លោកវេជ្ជបណ្ឌិត ឡាន វណ្ណាសេខ** អនុប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ៖

គោលបំណងនៃការអង្កេត គឺដើម្បីប៉ាន់ស្មានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ និងការប្រព្រឹត្តប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ និងមេរោគស្វាយ ក្នុងចំណោមស្ត្រីបម្រើសេវាកម្សាន្ត ។ ការអង្កេតលើស្ត្រីបម្រើសេវាកម្សាន្តចំនួន**៣១៥១** នាក់ត្រូវបានសម្ភាស ក្នុង១៨ខេត្ត និងរាជធានី។ ជារួមតាមរយៈការសន្និដ្ឋានទៅលើការអង្កេតយើងឃើញថា៖

- ការប្រើប្រាស់ស្រោមអនាម័យគ្រប់ពេលជាមួយនឹងអតិថិជនក្នុងចំណោមនារីបំរើសេវាកម្សាន្តសប្បាយ មានកម្រិតខ្ពស់៨៦-៨៧% ប៉ុន្តែជាមួយសង្សារ ជានិច្ចកាលនៅតែមានកម្រិតទាប និងបន្តធ្លាក់ចុះ (<៣០%) ។
- អត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមនារីបំរើសេវាកម្សាន្តសប្បាយ នៅថេរប្រសិនបើប្រៀបធៀបទៅនឹង HSS ឆ្នាំ២០១០ ប៉ុន្តែជំងឺស្វាយមានអត្រាទាបជាង១% ក្នុងចំណោមនារីបំរើសេវាកម្សាន្តសប្បាយ។

- ខេត្ត-ក្រុងមួយចំនួនមានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ខ្ពស់ ត្រូវបានគេសង្កេតឃើញមាននៅក្រុងភ្នំពេញ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តព្រះសីហនុ។
- គេសង្កេតឃើញអត្រាប្រេវ៉ាឡង់មេរោគអេដស៍ខ្ពស់ ពេលនារីបំរើសេវាកម្សាន្តសប្បាយមានអាយុចាប់ពី ៣០ឆ្នាំឡើង ប៉ុន្តែក្នុងចំណោមអាយុតិចជាង២៤ឆ្នាំ គឺមានអត្រាប្រេវ៉ាឡង់មេរោគអេដស៍ទាប (<១%) ជាពិសេសអាយុតិចជាង ២០ឆ្នាំគឺ (<0,៥%) ។

បន្ទាប់មកឯកឧត្តមប្រធានអង្គប្រជុំ ក៏បានជម្រាបជូនដល់សមាជិក-សមាជិកានៃអង្គប្រជុំថា **កិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី៩ នឹងប្រព្រឹត្តទៅនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៧** ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង១០នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត។

**ឧបសម្ព័ន្ធ៖**

- បញ្ជីវត្តមានអ្នកចូលរួម
- ឯកសារបទបង្ហាញផ្សេងៗ

ភ្នំពេញ ថ្ងៃទី 07 ខែមិថុនា ឆ្នាំ២០១៧

បានឃើញ និងឯកភាព
**អគ្គលេខាធិការ**

វេជ្ជ.តែង គន្ធី

ប្រធាននាយកដ្ឋាន
ទាក់ទង និងចលនាប្រកពធនធាន

**វេជ្ជ. ឈា សិទ្ធិ**